រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ១៧ សសរ**

**ស្តីពី**

**ការបង្កើតគណកម្មការទទួលបន្ទុករៀបចំបុណ្យសព**

**ឯកឧត្តម ឈា សុង រដ្ឋមន្ត្រីក្រសួងកសិកម្ម -រុក្ខាប្រមាញ់និងនេសាទ**

-យោងតាមសេចក្តីជូនដំណឹងរបស់ក្រសួងកសិកម្ម -រុក្ខាប្រមាញ់និងនេសាទ លេខ ១៣៥ ក.ស.ក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០១

- តាមការងារចំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ១:** បង្កើតគណកម្មការចំរុះមួយ ដើម្បីរៀបចំបុណ្យសព ឯកឧត្តម **ឈា សុង** ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ចំន្ទ តុងអ៊ីវ** | ប្រធាន |
| ២- ឯកឧត្តម | **មិន ឃិន** | អនុប្រធាន |
| ៣ - ឯកឧត្តម | **ស៊ុំ ម៉ានិត** | អនុប្រធាន |
| ៤- ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | អនុប្រធាន |
| ៥- ឯកឧត្តម | **ខៀវ កាញារិទ្ធ** | អនុប្រធាន |
| ៦ - ឯកឧត្តម | **ម៉ៅ សំអឿន** | អនុប្រធាន |
| ៧ - ឯកឧត្តម | **ចាយ សាំងយុន** | អនុប្រធាន |
| ៨ - ឯកឧត្តម | **ឈន អឿម** | សមាជិក |
| ៩ - ឯកឧត្តម | **ម៉ម ប៊ុនហេង** | សមាជិក |
| ១០- ឯកឧត្តម | **ប៊ុន អ៊ុយ** | សមាជិក |
| ១១ - ឯកឧត្តម | **សៅ សុខា** | សមាជិក |
| ១២- ឯកឧត្តម | **តេង សាវង្ស** | សមាជិក |
| ១៣ - ឯកឧត្តម | **ឃូ ស៊ុនឡុង** | សមាជិក |

www.pheakdeylaw.com

១៤-ឯកឧត្តម **អ៊ុក សុជាតិ** សមាជិក

១៥-ឯកឧត្តម **ជា សុខុម** សមាជិក

១៦-ឯកឧត្តម **ម៉ម សារិន** សមាជិក

១៧-ឯកឧត្តម **អ៊ិត សារ៉ាត** សមាជិក

១៨-ឯកឧត្តម **ញ៉េម ទារ៉ាលី** សមាជិក

**ប្រការ ២ :** គណកម្មការនេះមានភារកិច្ចទទួលបន្ទុករៀបចំបុណ្យសពឯក ឧត្តម **ឈា សុខ** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ឱ្យបានល្អប្រសើរ ស្របតាមប្រពៃណីជាតិ ប្រពៃណីសាសនា ជាកិត្តិយស ព្រមទាំងឱ្យបានសក្តិសម និងកិត្តយសរបស់សព ។

- រៀបចំកម្មវិធីលំអិត សំរាប់បុណ្យសព ពិធីការ ទទួលភ្ញៀវជាតិនិងអន្តរជាតិ ដែលត្រូវអញ្ជើញគោរព វិញ្ញាណក្ខ័ន្ធសព រៀបចំវិយោគកថា និងឯកសារផ្សេងៗដែលចាំបាច់ ។
- រៀបចំពិធីបុណ្យសពតាមប្រពៃណីសាសនា និងប្រពៃណីជាតិ ដោយសហការឱ្យបានជិតស្និទ្ធ ជាមួយ គ្រួសារសព ។
- ដោះស្រាយថវិកាសំរាប់បំរើការងាររៀបចំពិធីបុណ្យសព ។
- គណកម្មការនេះអាចបង្កើតអនុគណកម្មការជំនាញមួយចំនួនទៀតតាមតម្រូវការចាំបាច់ ដើម្បីជាជំនួយការ ។

សមាជិករបស់គណកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណកម្មការ ។

- រៀបចំក្បួនដង្ហែសព ពិធីដង្ហែសព និងពិធីបូជាសពឱ្យបានល្អប្រសើរ ។
- គណកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណកម្មការរៀបចំបុណ្យសព ឯកឧត្តម **ឈា សុខ** រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពគណកម្មការ ដូចមានចែងក្នុង ប្រការ១ ត្រូវអនុវត្តនូវសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

www.pheakdeylaw.com